# បទអន្តរាគមន៍របស់ឯកឧត្តម សយ កុសល ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥
# រាជធានីភ្នំពេញ ថ្ងៃទី ០៧-០៨ ខែ កញ្ញា ឆ្នាំ ២០២៦

សូមគោរព

- គណៈអធិបតី
- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
- ឯកឧត្តមប្រធានក្រុមប្រឹក្សារាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី

ជាបឋម ក្នុងនាមសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមថ្លែងបទអន្តរាគមន៍ នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ នាឱកាសនេះ និងសូមថ្លែងអំណរគុណក្រសួងមហាផ្ទៃដែលបានរៀបចំសន្និបាតបូកសរុបនេះឡើង។ ឆ្លៀតឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំបាទសូមចែករំលែកសមិទ្ធផលសំខាន់ៗ ដែលសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត សម្រេចបានក្នុងការគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំណែកអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់យកប្រជាជនជាស្នូលនៃការអភិវឌ្ឍ ជាពិសេសយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានកំណត់ចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច ការពង្រឹងអភិបាលកិច្ច ការបង្កើនការអភិវឌ្ឍសង្គម ការការពារបរិស្ថាន និងការលើកកម្ពស់គុណភាពជីវិតសម្រាប់ប្រជាជនកម្ពុជាទាំងអស់។

នៅក្នុងចក្ខុវិស័យជាតិដ៏ទូលំទូលាយនៃយុទ្ធសាស្ត្របញ្ចកោណ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាសសរស្តម្ភដ៏សំខាន់បំផុតមួយសម្រាប់ការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យ ការកែលម្អការផ្តល់សេវាសាធារណៈ និងការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព។ អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ កម្ពុជាបានបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថភាព មានការទទួលខុសត្រូវ និងមានការឆ្លើយតបយ៉ាងរឹងមាំ ដោយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋ ដើម្បីកំណត់អាទិភាពនៅមូលដ្ឋាន និងផ្តល់ដំណោះស្រាយជាក់ស្តែង។

ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការឆ្នោតនៅឆ្នាំ ២០០២ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងការអភិវឌ្ឍប្រជាធិបតេយ្យនៅកម្ពុជា។ ចាប់តាំងពីពេលនោះមក ក្រុមប្រឹក្សាឃុំ សង្កាត់ បានវិវត្តទៅជាមូលដ្ឋានគ្រឹះនៃអភិបាលកិច្ចមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជារដ្ឋបាលមូលដ្ឋានដែលនៅកៀកនឹងប្រជាជនបំផុត បានដើរតួនាទីជាចំណុចទំនាក់ទំនងដំបូងរវាងប្រជាពលរដ្ឋ និងរដ្ឋ។ ជារៀងរាល់ថ្ងៃ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្តាប់ក្តីកង្វល់របស់សហគមន៍ សម្របសម្រួលការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយវិវាទ គាំទ្រគ្រួសារងាយរងគ្រោះ ឆ្លើយតបនឹងគ្រោះអាសន្ន និងជំរុញសហគមន៍ឱ្យចូលរួមយ៉ាងសកម្មនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។

ជោគជ័យនៃកំណែទម្រង់វិមជ្ឈការរបស់កម្ពុជាត្រូវបានឆ្លុះបញ្ចាំងមិនត្រឹមតែនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលកាន់តែប្រសើរប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀត គឺនៅក្នុងការកែលម្អជាក់ស្តែងដែលប្រជាពលរដ្ឋទទួលបាននៅទូទាំងប្រទេស។ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ត្រូវបានពង្រីកគួរឱ្យកត់សម្គាល់ ការទទួលបានសេវាសាធារណៈកាន់តែប្រសើរ ការចូលរួមរបស់ប្រជាពលរដ្ឋ មានការកើនឡើង ដំណើរការរៀបចំផែនការ និងថវិកានៅមូលដ្ឋានកាន់តែមានតម្លាភាព ស្ត្រីបានដើរតួនាទីជាអ្នកដឹកនាំកាន់តែសំខាន់នៅក្នុងអភិបាលកិច្ចមូលដ្ឋាន សហគមន៍កាន់តែមានភាពធន់នឹងគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។ សមិទ្ធផលទាំងនេះបង្ហាញថា វិមជ្ឈការមិនមែនគ្រាន់តែជាកំណែទម្រង់ស្ថាប័ននោះទេ ប៉ុន្តែគឺជាកំណែទម្រង់ដែលធ្វើឱ្យជីវិតប្រចាំថ្ងៃរបស់ប្រជាជនប្រសើរឡើង។

មេរៀន បទពិសោធដ៏សំខាន់ដែលយើងអាចទទួលបានពីអន្តរជាតិ គឺថាការធ្វើវិមជ្ឈការប្រកបដោយជោគជ័យមិនមែនសម្រេចបានតែតាមរយៈកំណែទម្រង់ផ្នែកច្បាប់ ឬស្ថាប័នទេ។ វិមជ្ឈការប្រកបដោយជោគជ័យ ត្រូវសម្រេចបានតាមរយៈស្ថាប័នរឹងមាំ រដ្ឋបាលមូលដ្ឋានដែលមានសមត្ថភាព និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ដែលប្រែក្លាយគោលនយោបាយជាតិទៅជាការកែលម្អជាក់ស្តែងទៅលើជីវភាពរស់នៅរបស់ប្រជាជនរបស់យើង។

**ឯកឧត្តម លោកជំទាវ ជាទីគោរព!**

**លោក លោកស្រី ជាទីមេត្រី!**

ទស្សនាទាននៃការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានពិភាក្សាជាមួយប្រតិភូក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានអញ្ជើញចូលរួមនៅក្នុងសន្និបាតក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសលើកទីមួយនៅក្រសួងមហាផ្ទៃ នាថ្ងៃទី៧-៩ ខែមេសា ឆ្នាំ២០០៣។ ប្រតិភូក្រុមប្រឹក្សាឃុំ សង្កាត់ បានឯកភាពទស្សនាទាននេះ ហើយបានសំដែងការប្តេជ្ញាចិត្តក្នុងការរៀបចំបង្កើតសមាគមឲ្យទទួលបានជោគជ័យ។ ជាមួយគ្នានេះ នៅក្នុងឱកាសបិទសន្និបាត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្រ្តី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានសំដែងក្តីសោមនស្សរីករាយ ដោយសម្តេចបានជ្រាបថា នៅក្នុងសន្និបាតនេះ មានការពិគ្រោះពិភាក្សា និងការប្រមូលគំនិតនានាអំពីការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចបានចាត់ទុកថា សមាគមនេះ នឹងដើរតួនាទី និងជាដៃគូយ៉ាងសំខាន់នៅក្នុងការជំរុញដំណើរការវិមជ្ឈការ និងការអនុវត្តអភិបាលកិច្ចមូលដ្ឋាន។ នៅក្នុងការរៀបចំបង្កើតសមាគម សម្តេច បានណែនាំឲ្យយកចិត្តទុកដាក់ផ្សារភ្ជាប់លក្ខណៈជាក់ស្តែងនៅកម្ពុជា ហើយត្រូវមានទិសដៅច្បាស់លាស់ មានការទទួលខុសត្រូវ និងត្រូវធ្វើការថ្លឹងថ្លែងអំពីសមត្ថភាពរបស់សមាគមផងដែរ ។

ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា ជាពិសេស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវបានបង្កើតឡើង តាមរយៈមហាសន្និបាតនៅឆ្នាំ ២០០៦ ជាស្ថាប័នមួយដែលតំណាងឲ្យសំឡេងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ ជាមួយនឹងការបង្កើតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ តាមរយៈការបោះឆ្នោតនៅឆ្នាំ ២០០៩ និងដោយមានការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានសម្របសម្រួលការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌអំពីការបង្កើតស្ថាប័នរួមមួយដែលតំណាងឲ្យក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ដោយមានការឯកភាពក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ក្នុងការបង្កើតស្ថាប័នរួមនេះ និងដោយផ្អែកលើបទពិសោធ និងសមិទ្ធផលដែលសម្រេចបានដោយសម្ព័ន្ធភាពជាតិឃុំ សង្កាត់ មហាសន្និបាតពង្រីកសម្ព័ន្ធភាពជាតិ ត្រូវបានរៀបចំឡើងនៅថ្ងៃទី ៣០-៣១ ខែកក្កដា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចក្រឡាហោម ស ខេង** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយបញ្ចូលក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បង្កើតជា "**សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា**" ហៅកាត់ថា "**សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន**"។

នៅតាមបណ្តាប្រទេសជាច្រើននៅលើពិភពលោក សមាគមរដ្ឋបាលមូលដ្ឋានបានក្លាយជាដៃគូដ៏សំខាន់របស់រដ្ឋាភិបាលក្នុងការជំរុញការអនុវត្តវិមជ្ឈការ និងការពង្រឹងប្រជាធិបតេយ្យនៅមូលដ្ឋាន។ សមាគមទាំងនេះ មិនជំនួសឱ្យការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលឡើយ។ ផ្ទុយទៅវិញ សមាគមបំពេញការងារក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល ដោយបំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបា

លក្នុងការពង្រឹងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាន លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋបាលមូលដ្ឋាន សម្របសម្រួលការផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ និងធានាថារដ្ឋបាលមូលដ្ឋាន មានការយល់ដឹងល្អអំពីគោលនយោបាយជាតិ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

សមាគមរដ្ឋបាលមូលដ្ឋាន គឺជាវេទិកាផ្នែកស្ថាប័នដែលតាមរយៈវេទិកានេះ រដ្ឋបាលមូលដ្ឋាន អាចចែករំលែកបទពិសោធ និងព័ត៌មានជាក់ស្តែង កំណត់បញ្ហាប្រឈមដែលកំពុងកើតឡើង និងចូលរួមចំណែកអនុសាសន៍ជាលក្ខណៈស្ថាបនា ដើម្បីកែលម្អគោលនយោបាយសាធារណៈ។ តាមរយៈការ លើកកម្ពស់ការសន្ទនាជាបន្តបន្ទាប់រវាងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគមជួយធានាថា វិមជ្ឈការមានលក្ខណៈឆ្លើយតប និងផ្តោតលើការកែលម្អគុណភាពនៃសេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋ។ បទពិសោធអន្តរជាតិក៏បង្ហាញបន្ថែមទៀតថា ប្រទេសដែលមានសមាគមរដ្ឋបាលមូលដ្ឋានរឹងមាំ និងមានប្រសិទ្ធភាព តែងតែមានជំហរល្អប្រសើរក្នុងការកសាងភាពជាអ្នកដឹកនាំនៅមូលដ្ឋានប្រកបដោយវិជ្ជាជី-វៈ ពង្រឹងការទទួលខុសត្រូវ និងតម្លាភាព លើកទឹកចិត្តនវានុវត្តន៍ គៀរគរភាពជាដៃគូ និងលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព។ សមាគមនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយរដ្ឋបាលមូលដ្ឋានរៀនសូត្រពីគ្នាទៅវិញទៅមក កែលម្អការអនុវត្តរបស់គាត់ជាបន្តបន្ទាប់ និងឆ្លើយតបកាន់តែមានប្រសិទ្ធភាពចំពោះតម្រូវការ និងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋនៅសហគមន៍។

សម្រាប់ប្រទេសកម្ពុជា បទពិសោធទាំងនេះមានភាពជាក់ស្តែងខ្លាំង។ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់រាជរដ្ឋាភិបាល វឌ្ឍនភាពគួរឱ្យកត់សម្គាល់ត្រូវបានធ្វើឡើងក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។ នៅពេលដែលកំណែទម្រង់ទាំងនេះមានការវិវត្តជាបន្តបន្ទាប់ សម្ព័ន្ធជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើរតួនាទីដ៏សំខាន់ក្នុងភាពជាដៃគូស្ថាបនារបស់រាជរដ្ឋាភិបាល។ តាមរយៈការប្រើប្រាស់ប្រាក់សមាជិកភាព និងការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ ប្រាក់ឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ក្នុងរយៈកាលកន្លងមកនេះ សម្ព័ន្ធភាពជាតិ បានបន្តពុះពារយ៉ាងស្វាហាប់ក្នុងការផ្តល់សេវាកសាងសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់មូលដ្ឋាន ជាពិសេសសមាជិកក្រុមប្រឹក្សាដែលទើបជាប់ឆ្នោតថ្មីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងផ្តល់ជំនាញ វិជ្ជាជីវៈ និងការលើកកម្ពស់ឋានៈ ការការពារ និងការស្វែងរកការគាំទ្រជាប្រយោជន៍ស្របច្បាប់ជូនសមាជិក។ សម្ព័ន្ធភាពជាតិបានដើរតួនាទីជាវេទិកាឱ្យក្រុមប្រឹក្សាមូលដ្ឋានបង្ហាញអាទិភាព ក្តីកង្វល់ និងអនុសាសន៍របស់ខ្លួន ព្រមទាំងសម្របសម្រួលការសន្ទនាប្រកបដោយស្ថាបនារវាងថ្នាក់មូលដ្ឋាន និងស្ថាប័នថ្នាក់ជាតិ។ តាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និងការផ្លាស់ប្តូរចំណេះដឹង បទពិសោធ សម្ព័ន្ធភាពជាតិបានចូលរួមជួយឱ្យក្រុមប្រឹក្សាមូលដ្ឋានបន្តកែលម្អការអនុវត្តរបស់ខ្លួន។ សម្ព័ន្ធភាពជាតិក៏បានយកចិត្តទុកដាក់ផងដែរលើការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសង្គម ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន កិច្ចសហប្រតិបត្តិការជាមួយ

រដ្ឋបាលមូលដ្ឋានអន្តរជាតិ ការធ្វើមូលដ្ឋានីយកម្មនៃ SDGs និងការលើកកម្ពស់នវានុវត្តន៍ និង បរិវត្តកម្មឌីជីថល ។

ក្នុងនាមប្រធានសម្ព័ន្ធជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ខ្ញុំពិតជាមានការលើកទឹកចិត្តជាពិសេសចំពោះការលះបង់ ភាពធន់ និងវិជ្ជាជីវៈដែលបានបង្ហាញដោយក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស។ ទោះបីជាមានបញ្ហាប្រឈមជាច្រើន ដូចជា ជំងឺរាតត្បាតកូវីដ-១៩ គ្រោះមហន្តរាយធម្មជាតិ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងអំពើឈ្លានពានពីសំណាក់កងទ័ពថៃមកលើដែនអធិបតេយ្យភាពកម្ពុជាក្តី ក៏ក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែរឹងមាំក្នុងការបម្រើប្រជាជន។ ការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានរបស់ប្រទេសកម្ពុជា និងទំនុកចិត្តដែលប្រជាពលរដ្ឋមានចំពោះតំណាងដែលគាត់បានបោះឆ្នោតជ្រើសរើស។

សន្និបាតនេះផ្តល់ឱ្យយើងនូវឱកាសមិនត្រឹមតែដើម្បីអបអរសាទរសមិទ្ធផលរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមដែលនៅសេសសល់ផងដែរ។ តាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក ការពង្រឹងកិច្ចសហការរវាងរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងសហគមន៍មូលដ្ឋាន យើងអាចបន្តកសាងរដ្ឋបាលមូលដ្ឋានដែលកាន់តែមានសមត្ថភាព កាន់តែមានការទទួលខុសត្រូវ កាន់តែមានភាពធន់ និងត្រៀមខ្លួនបានកាន់តែប្រសើរ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋរបស់យើង។

មុននឹងបញ្ចប់បទអន្តរាគមន៍ ក្នុងនាមជាអ្នកតំណាងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ខ្ញុំបាទសូមលើកឡើងនូវសំណូមពរចំនួន ៥ ចំណុច ដូចខាងក្រោមៈ

**ទី ១**. ស្នើសុំរាជរដ្ឋាភិបាលពន្លឿនការដាក់ចេញគោលនយោបាយស្តីពីការផ្តល់ប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សាដែលបានជាប់ឆ្នោតចាប់ពី ៣ អាណត្តិឡើង ជាពិសេសស្នើសុំការដាក់ចេញគោលនយោបាយនេះនៅក្នុងអំឡុងពេលដាក់បញ្ជីបេក្ខជនជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៦។

**ទី ២**. នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិទី ៦ និងអាណត្តិជាបន្តបន្ទាប់ទៀត សូមស្នើសុំបង្កើនចំនួនស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការគិតគូរពិចារណាដល់បេក្ខភាពជាស្ត្រីនៅលើលំដាប់លេខរៀងដែលអាចជាប់ឆ្នោតជាមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**ទី ៣**. ដើម្បីធានាដល់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលជាថវិកាជាតិប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សូមស្នើសុំពង្រឹងដំណើរការលទ្ធកម្មគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់។

**ទី ៤.** ស្នើសុំផ្តល់ការទទួលស្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានស្នាដៃឆ្នើម តាមរយៈការបំពាក់គ្រឿងឥស្សរិយយស និងមេដាយការងារនៅក្នុងសន្និបាតប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត។

**ទី ៥.** ស្នើសុំពង្រឹងការកសាងសមត្ថភាពមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូប តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា កម្មវិធីផ្លាស់ប្តូរចំណេះដឹង និងបទពិសោធការងារ។

ជាថ្មីម្តងទៀត អនុញ្ញាតឱ្យខ្ញុំបានថ្លែងអំណរគុណចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិដែលបានផ្តល់ការគាំទ្រចូលរួមលើកទឹកចិត្តឲ្យយើងខ្ញុំជាអាជ្ញាធរមូលដ្ឋាននៅកៀកបំផុតនឹងប្រជាពលរដ្ឋ ហើយឆ្លើយតបទៅប្រជាពលរដ្ឋយ៉ាងឆាប់បំផុត ដើម្បីមានការប្តេជ្ញាចិត្តកាន់តែសកម្មទ្វេឡើងក្នុងការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចមូលដ្ឋាន និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ដែលបានជួយគាំទ្រ និងនៅតែបន្តគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

ទីបញ្ចប់ខ្ញុំសូមគោរពជូនពរឯកឧត្តមអភិសន្តិបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការបំពេញគ្រប់ភារកិច្ច។

**សូមអរគុណ** !